Australian Government
Services Australia

KHMER

# ព័ត៌មានសម្រាប់អ្នកថែទាំ

យើងផ្តល់ជូនការបង់ប្រាក់ដល់មនុស្សដែលថែទាំអ្នកណាម្នាក់។

## Carer Payment

ដើម្បីទទួលបានការបង់ប្រាក់នេះ អ្នកត្រូវតែផ្តល់ការថែទាំជាញឹកញាប់ដល់អ្នកណាម្នាក់ដែលមាន៖

- ពិការភាព
- លក្ខខណ្ឌផ្នែកវេជ្ជសាស្ត្រ
- មនុស្សពេញវ័យដែលមានអាយុចាស់ទន់ខ្សោយ។

អ្នក និងមនុស្សដែលអ្នកផ្តល់ការថែទាំនោះត្រូវតែនៅនៅក្រោមដែនកំណត់នៃការធ្វើតេស្តប្រាក់ចំណូល និងទ្រព្យសម្បត្តិ។

អ្នកត្រូវតែ៖

- ផ្តល់ការថែទាំជាញឹកញាប់ដល់អ្នកណាម្នាក់ដែលត្រូវការការថែទាំសម្រាប់រយៈពេលយ៉ាងតិច 6 ខែ ឬមានជំងឺរង់ចាំតែពេលស្លាប់
- ថែទាំពួកគេនៅក្នុងផ្ទះរបស់ពួកគេ
- មិនចំណាយពេលច្រើនជាង 100 ម៉ោង ក្នុងរយៈពេល 4 សប្តាហ៍ ចេញពីការថែទាំដើម្បីធ្វើការដែលមានបង់ប្រាក់ រួមមានការងារខ្លួនឯង។

## Carer Allowance

ដើម្បីទទួលបានប្រាក់ឧបត្ថម្ភនេះ អ្នកត្រូវតែផ្តល់ការថែទាំប្រចាំថ្ងៃ និងការយកចិត្តទុកដាក់ដល់អ្នកណាម្នាក់ដែលមានពិការភាព ឬលក្ខខណ្ឌផ្នែកវេជ្ជសាស្ត្រ ឬមនុស្សពេញវ័យដែលមានអាយុចាស់ទន់ខ្សោយ។

អ្នកត្រូវតែ៖

- ផ្តល់ការថែទាំប្រចាំថ្ងៃដល់អ្នកណាម្នាក់ដែលត្រូវការការថែទាំរយៈពេលយ៉ាងតិច 12 ខែ ឬមានជំងឺរង់ចាំតែថ្ងៃស្លាប់
- ថែទាំពួកគេនៅផ្ទះរបស់ពួកគេ ឬនៅផ្ទះរបស់អ្នក
- ស្ថិតនៅក្រោមការធ្វើតេស្តប្រាក់ចំណូល Carer Allowance។

## Carer Supplement

នេះជាការបង់ប្រាក់ប្រចាំឆ្នាំដែលមានប្រាក់រហូតដល់ $600 សម្រាប់អ្នកទាំងនោះដែលមានសិទ្ធិទទួលបានការបង់ប្រាក់ដើម្បីផ្តល់ការថែទាំសម្រាប់មនុស្សម្នាក់ដែលមានពិការភាព ឬលក្ខខណ្ឌផ្នែកវេជ្ជសាស្ត្រ។ វាត្រូវបានបង់ឱ្យជាស្វ័យប្រវត្តិនៅខែកក្កដា ក្នុងឆ្នាំនីមួយៗ។

## Child Disability Assistance Payment

នេះជាការបង់ប្រាក់ប្រចាំឆ្នាំដែលមានប្រាក់រហូតដល់ $1,000 សម្រាប់អ្នកទាំងនោះដែលទទួលបាន Carer Allowance នៅពេលមើលថែទាំកូនដែលមានពិការភាព ឬលក្ខខណ្ឌផ្នែកវេជ្ជសាស្ត្រ។ វាត្រូវបានបង់ឱ្យជាស្វ័យប្រវត្តិនៅខែកក្កដា ក្នុងឆ្នាំនីមួយៗ។

## Carer Adjustment Payment

ដើម្បីទទួលបានការបង់ប្រាក់តែមួយដងនេះ អ្នកត្រូវតែផ្តល់ការថែទាំពេញម៉ោងដល់កូនដែលមានអាយុក្មេងជាង 7 ឆ្នាំ ដែលបានធ្វើរោគវិនិច្ឆ័យថាមានពិការភាពធ្ងន់ធ្ងរ ឬលក្ខខណ្ឌផ្នែកវេជ្ជសាស្ត្រធ្ងន់ធ្ងរ ក្រោយព្រឹត្តិការណ៍អន្តរាយមួយ។

អ្នកត្រូវតែ៖

- ទាមទារក្នុងរយៈពេល 2 ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការធ្វើរោគវិនិច្ឆ័យ
- ថែទាំកូនរយៈពេលយ៉ាងងតិច 2 ខែ ក្រោយព្រឹត្តិការណ៍អន្តរាយនោះ
- មានសេចក្តីត្រូវការខ្លាំងណាស់សម្រាប់ជំនួយផ្នែកហិរញ្ញវត្ថុ
- ទទួលបាន Carer Allowance សម្រាប់កូន
- ធ្វើឱ្យប្រាកដថាអ្នក និងដៃគូរបស់អ្នកមិនអាចទទួលបានការបង់ប្រាក់គាំទ្រប្រាក់ចំណូល។

## ការទាមទារការបង់ប្រាក់អ្នកថែទាំ

នៅថ្ងៃនៃការទាមទារ ទាំងអ្នក និងមនុស្សដែលអ្នកថែទាំត្រូវតែជាអ្នករស់នៅអចិន្ត្រៃយ៍អូស្ត្រាលី ដែលកំពុងរស់នៅក្នុងប្រទេសអូស្ត្រាលី។

អ្នកក៏ត្រូវតែមានវត្តមានខ្លួននៅក្នុងប្រទេសអូស្ត្រាលីនៅថ្ងៃដែលអ្នកទាមទារ។

ប្រសិនបើអ្នកមាន Centrelink online account, អ្នកអាចចុះឈ្មោះចូលទៅក្នុង myGov និងទាមទារ Carer Payment, Carer Allowance ឬទាមទារទាំងពីរតាមអនឡាញ។

អ្នកក៏អាចហៅទូរសព្ទទៅ Disability, sickness and carers line តាមលេខ **132 717** ឬចូលទៅមជ្ឈមណ្ឌលសេវាកម្មដែលនៅជិតបំផុតរបស់អ្នក។

## ការផ្លាស់ប្តូរនៃកាលៈទេសៈ

អ្នកត្រូវប្រាប់យើងក្នុងរយៈពេល 14 ថ្ងៃអំពីការផ្លាស់ប្តូរផ្ទាល់ខ្លួន ការផ្លាស់ប្រាក់ចំណូល ឬការផ្លាស់ប្តូរការថែទាំ។ ប្រសិនបើអ្នកមិនប្រាប់យើងអំពីការផ្លាស់ប្តូរទាំងនេះទេ យើអាចបង់ឱ្យអ្នកច្រើនពេក។ ប្រសិនបើរឿងនេះកើតឡើង អ្នកនឹងត្រូវតែបង់ប្រាក់សងត្រឡប់មកវិញ។

នេះអាចរួមមាន ប៉ុន្តែមិនកំណត់ចំពោះ៖

- បរិមាណនៃការថែទាំដែលពួកគេត្រូវការផ្លាស់ប្តូរ
- អ្នកឈប់ផ្តល់ការថែទាំ ឬចាប់ផ្តើមចែករំលែកការថែទាំជាមួយអ្នកណាម្នាក់ផ្សេងទៀត
- អ្នក ឬមនុស្សដែលអ្នកថែទាំទៅបរទេស
- ការផ្លាស់ប្តូរណាមួយចំពោះទំនាក់ទំនងរបស់អ្នក
- ការផ្លាស់ប្តូរណាមួយចំពោះប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់អ្នក។

អ្នកត្រូវតែប្រាប់យើង ប្រសិនបើមនុស្សដែលអ្នកផ្តល់ការថែទាំ៖

- គឺស្ថិតនៅក្នុងការថែទាំរបស់អ្នកណាម្នាក់ផ្សេងទៀត
- ចូលទៅនៅក្នុងការថែទាំពេលវិស្សមកាល មន្ទីរពេទ្យ ឬផ្លាស់ទៅផ្ទះថែទាំមនុស្សចាស់
- ឈប់ជាកូននៅក្នុងបន្ទុក
- ទៅរស់នៅក្រៅប្រទេសអូស្ត្រាលី
- ស្លាប់។

## Carer Gateway

Carer Gateway គឺជាកម្មវិធីរដ្ឋាភិបាលអូស្ត្រាលីដែលផ្តល់សេវាកម្ម និងការគាំទ្រដោយឥតគិតថ្លៃសម្រាប់អ្នកថែទាំនានា។ សេវាកម្មរបស់ពួកគេរួមមានក្រុមគាំទ្រ កញ្ចប់គាំទ្រ និងការពិគ្រោះយោបល់។ ទៅកាន់ **carergateway.gov.au** ឬហៅទូរសព្ទទៅពួកគេតាមលេខ **1800 422 737** សម្រាប់ព័ត៌មានបន្ថែម។

## សម្រាប់ព័ត៌មានបន្ថែម

- ទៅកាន់ **servicesaustralia.gov.au/carers** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស។
- ទៅកាន់ **servicesaustralia.gov.au/yourlanguage** ដែលជាកន្លែងដែលអ្នកអាចអាន ស្តាប់ ឬមើលវីដេអូជាភាសារបស់អ្នកបាន។
- សូមហៅទូរសព្ទទៅលេខ **131 202** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នកអំពីការបង់ប្រាក់ និងសេវាកម្ម Centrelink។
- សូមហៅទូរសព្ទទៅលេខ **132 011** សម្រាប់ Medicare និងលេខ **131 272** សម្រាប់ Child Support។ សូមប្រាប់ឱ្យយើងដឹងប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ហើយយើងនឹងចាត់ចែងឱ្យមានអ្នកបកប្រែផ្ទាល់មាត់ដោយឥតគិតថ្លៃ។
- ចូលទៅទស្សនាមជ្ឈមណ្ឌលសេវាកម្ម។

**ចំណាំ**: ការហៅទូរសព្ទតាមទូរសព្ទភ្ជាប់ខ្សែទៅលេខ ‘13’ ពីកន្លែងណាមួយក្នុងប្រទេសអូស្ត្រាលីត្រូវបានគិតថ្លៃតាមអត្រាថេរ។ អត្រានោះអាចប្រែប្រួលពីតម្លៃនៃការហៅទូរសព្ទតាមតំបន់ ហើយក៏អាចប្រែប្រួលផងដែរក្នុងចំណោមអ្នកផ្តល់សេវាទូរសព្ទនានា។ ហៅទូរសព្ទទៅលេខ ‘18’ ពីទូរសព្ទភ្ជាប់ខ្សែរបស់អ្នកជាធម្មតាគឺឥតគិតថ្លៃ។ ការហៅទូរសព្ទពីទូរសព្ទសាធារណៈ និងពីទូរសព្ទចល័តអាចត្រូវបានកំណត់ម៉ោង ព្រមទាំងត្រូវបានគិតថ្លៃតាមអត្រាកាន់តែខ្ពស់។

## ការប្រកាសមិនទទួលខុសត្រូវ

ព័ត៌មានដែលមាននៅក្នុងការបោះផ្សាយនេះមានគោលបំណងតែជាការណែនាំចំពោះការបង់ប្រាក់ និងសេវាកម្មនានាប៉ុណ្ណោះ។ វាជាការទទួលខុសត្រូវរបស់អ្នកក្នុងការសម្រេចចិត្ត ប្រសិនបើអ្នកប្រាថ្នាចង់ដាក់ពាក្យដើម្បីទទួលបានការបង់ប្រាក់ និងដើម្បីធ្វើការដាក់ពាក្យសុំទាក់ទងនឹងកាលៈទេសៈពិសេសរបស់អ្នក។

# Information for carers

We offer payments to people who care for someone.

## Carer Payment

To get this payment you must give constant care to someone with:

- disability
- a medical condition
- an adult who is frail aged.

You and the person you provide care for must be under the income and assets test limits.

You must:

- give constant care to someone who needs care for at least 6 months, or has a terminal illness
- care for them in their home
- not spend more than 100 hours in a 4 week period away from care to do paid work, including self-employment.

## Carer Allowance

To get this allowance you must give daily care and attention to someone with disability or a medical condition or an adult who is frail aged.

You must:

- give daily care to someone who needs care for at least 12 months, or has a terminal illness
- care for them in either their home or your home
- be under the Carer Allowance income test.

## Carer Supplement

This is an annual payment of up to $600 for those who get an eligible payment to provide care for a person with disability or a medical condition. It is paid automatically in July each year.

## Child Disability Assistance Payment

This is an annual payment of up to $1,000 for those who get Carer Allowance when looking after a child with disability or a medical condition. It is paid automatically in July each year.

## Carer Adjustment Payment

To get this one-off payment, you must give full-time care to a child younger than 7 years of age who has been diagnosed with a severe disability or severe medical condition following a catastrophic event.

You must:

- claim within 2 years from the date of diagnosis
- care for the child for at least 2 months after the catastrophic event

- have a very strong need for financial help
- get Carer Allowance for the child
- make sure you and your partner cannot get an income support payment.

## Claiming carer payments

On the day of claiming, both you and the person you care for must be Australian residents living in Australia.

You must also be physically in Australia the day you claim.

If you have a Centrelink online account, you can sign into myGov and claim Carer Payment, Carer Allowance or both online.

You can also call the Disability, sickness and carers line on **132 717** or visit your nearest service centre.

## Change of circumstances

You need to tell us within 14 days about any personal, income or care changes. If you do not tell us about these changes, we may pay you too much. If this happens, you will have to pay the money back.

This can include, but is not limited to:

- the amount of care they need changes
- you stop providing care or start sharing the care with someone else
- you or the person you care for go overseas
- any changes to your relationship
- any changes to your income and assets.

You must also tell us if the person you provide care for:

- is in someone else's care
- goes into respite care, hospital or moves to a nursing home
- stops being a dependent child
- goes to live outside Australia
- dies.

## Carer Gateway

Carer Gateway is an Australian Government program providing free services and support for carers. Their services include peer support groups, support packages and counselling. Go to **carergateway.gov.au** or call them on **1800 422 737** for more information.

## For more information

- Go to **servicesaustralia.gov.au/carers** for more information in English.
- Go to **servicesaustralia.gov.au/yourlanguage** where you can read, listen to or watch videos in your language.
- Call **131 202** to speak with us in your language about Centrelink payments and services.

- Call **132 011** for Medicare and **131 272** for Child Support. Let us know if you need an interpreter, and we will arrange one for free.
- Visit a service centre.

**Note**: calls from your landline to ‘13’ numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to ‘18’ numbers from your landline are usually free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It’s your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.